ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតអគ្គលេខាធិការដ្ឋានថេរសភា នៃពុទ្ធសាសនានៅព្រះរាជាណាចក្រកម្ពុជា

ចែករំលែកដោយៈ មេធាវីឥស្រាច្បាប់
www.legalcodelawfim.com
www.facebook.com/legalcodelawfim
App Store & Play Store: LEGAL CODE（ឥស្រាច្បាប់）

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៧៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតអគ្គលេខាធិការដ្ឋានថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា
- យោងសំណើលេខ ០៥៣/២០ ស.ន.ក.ជ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ របស់គណៈសង្ឃនាយក ស្តីពីការរៀបចំដំឡើងឋានៈ និងតែងតាំងមន្ត្រីសង្ឃជាន់ខ្ពស់ ក្នុងស្ថាប័នថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា និងបង្កើតអគ្គលេខាធិការដ្ឋាន

## សម្រេច

**មាត្រា១ ៖** ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ ៖** អគ្គលេខាធិការដ្ឋានថេរសភា នៃពុទ្ធសាសនា ជាសេនាធិការឱ្យថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយអគ្គលេខាធិការ ១អង្គ និងអគ្គលេខាធិការរង ២អង្គ។

**មាត្រា៣ ៖** អគ្គលេខាធិការដ្ឋាន មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

-ដំណើរការកិច្ចការរដ្ឋបាលទូទៅរបស់ថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា
-សម្របសម្រួលការប្រព្រឹត្តទៅរបស់ថេរសភា នៃពុទ្ធសាសនា
-ទទួលសំណុំអធិករណ៍ពីគណៈសង្ឃនាយក និងរៀបចំឯកសារ ប្រគេនថ្នាក់ដឹកនាំថេរសភា នៃពុទ្ធសាសនា ដើម្បីដោះស្រាយ និងជំនុំជម្រះ
-រៀបចំដំណើរបេសកកម្មរបស់ថ្នាក់ដឹកនាំថេរសភា នៃពុទ្ធសាសនា

-ចាត់ចែងរៀបចំការប្រជុំរបស់ថេរសភា នៃពុទ្ធសាសនា
-រៀបចំវគ្គបណ្ដុះបណ្ដាលដល់មន្ត្រីសង្ឃថេរសភារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ
-រៀបចំក្រុមចុះស្រាវជ្រាវស៊ើបអង្កេតអធិករណ៍តាមករណីជាក់ស្ដែង
-ប្រមូលព័ត៌មានដែលទាក់ទងនឹងអធិករណ៍ពុទ្ធសាសនា
-ស្រាវជ្រាវ និងប្រមូលចងក្រងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ
-ធ្វើកំណត់ហេតុប្រជុំរបស់ថេរសភា នៃពុទ្ធសាសនា
-ធ្វើទំនាក់ទំនងជាមួយអាជ្ញាធរពាក់ព័ន្ធ និងតុលាការខាងអាណាចក្រ
-ការងារបញ្ជូនសំណុំអធិករណ៍ទៅថ្នាក់ដឹកនាំថេរសភា នៃពុទ្ធសាសនា
-ធ្វើទំនាក់ទំនងជាមួយលេខាធិការដ្ឋានគណៈសង្ឃនាយក
-ការងារទំនាក់ទំនងសាធារណៈ
-ការងារគ្រប់គ្រងបច្ចេកទេស សម្រាប់កម្មវិធីការងារជម្រះអធិករណ៍
-អនុវត្តការងារផ្សេងៗទៀត តាមការកំណត់នៃលិខិតបទដ្ឋានគតិយុត្ត
-ទទួលការងារផ្សេងៗទៀត តាមការចង្អុលបង្ហាញរបស់ប្រធានថេរសភា នៃពុទ្ធសាសនា
-ធ្វើរបាយការណ៍តាមរបបកំណត់ និងរបាយការណ៍ជំនាញ ថ្វាយទៅគណៈសង្ឃនាយក

**មាត្រា៤ ៖** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.សុក្រ.១៣.កើត.ខែ.ផល្គុន....ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី.......៦.....ខែ..មីនា.......ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
-សម្ដេចព្រះមហាសង្ឃរាជទាំងពីរគណៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យទីស្ដីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ
-ថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ
-ដូចមាត្រា៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ